**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**០៨...សសរ.....

# សេចក្ដីសម្រេច

## ស្ដីពី

## ការបន្ថែមសមាសភាពក្រុមការងារអន្តរក្រសួង ដើម្បីចុះសិក្សា និងដោះស្រាយករណីរកឃើញគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងនាវាដែលលិចក្នុងទន្លេ ស្ថិតនៅភូមិវាល ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៨៩ សសរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ស្ដីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចុះសិក្សា និងដោះស្រាយករណីរកឃើញគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងនាវាដែលលិចក្នុងទន្លេ ស្ថិតនៅភូមិវាល ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.-**

ត្រូវបានបន្ថែមសមាសភាពក្រុមការងារអន្តរក្រសួង ដើម្បីចុះសិក្សា និងដោះស្រាយករណីរកឃើញគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងនាវាដែលលិចក្នុងទន្លេ ស្ថិតនៅភូមិវាល ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដែលមានដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម **ជា សុមេធី** | អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង | សមាជិក |
| ២.ឯកឧត្តម **គង់ សោភ័ណ្ឌ** | អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល | សមាជិក |
| ៣.ឯកឧត្តម នាយឧត្តមសេនីយ៍ **ជា សុគន្ធា** | អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ | សមាជិក |

៤. ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង សមាជិក

៥. ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល សមាជិក

៦. អភិបាល នៃគណៈអភិបាលស្រុកខ្សាច់កណ្ដាល សមាជិក

៧. អភិបាល នៃគណៈអភិបាលស្រុកល្វាឯម សមាជិក

៨. អភិបាល នៃគណៈអភិបាលស្រុកពាមរក៍ សមាជិក

៩. អភិបាល នៃគណៈអភិបាលស្រុកពាមជរ សមាជិក

១០. អធិការ នៃអធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល សមាជិក

១១. អធិការ នៃអធិការដ្ឋាននគរបាលស្រុកល្វាឯម សមាជិក

១២. អធិការ នៃអធិការដ្ឋាននគរបាលស្រុកពាមរក៍ សមាជិក

១៣. អធិការ នៃអធិការដ្ឋាននគរបាលស្រុកពាមជរ សមាជិក

**ប្រការ២.-**

- សមាសភាពដូចមានក្នុងប្រការ១ ត្រូវអនុវត្តតួនាទី ភារកិច្ច ដូចមានចែងក្នុងសេចក្ដីសម្រេចលេខ ៨៩ សសរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា។
- ក្រុមការងារអន្តរក្រសួងត្រូវចុះសិក្សា និងដោះស្រាយករណីកេឃើញគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងនាវាដែលលិចក្នុងទន្លេ បន្ថែមលើភូមិសាស្ត្រ ភូមិកោះកោងមួយ ឃុំព្រែកដំបង ស្រុកខ្សាច់កណ្ដាល និងភូមិបឹងគ្រុំ ឃុំបឹងគ្រុំ ស្រុកល្វាឯម ខេត្តកណ្ដាល ។
- ក្រុមការងារអន្តរក្រសួងត្រូវចុះសិក្សា និងដោះស្រាយករណីកេឃើញគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះក្នុងនាវាដែលលិចក្នុងទន្លេ បន្ថែមលើភូមិសាស្ត្រ ភូមិបឹងក្អែក ឃុំពាមមានជ័យ ស្រុកពាមរក៍ និងភូមិកោះពាមរាំង ឃុំកោះចេក ស្រុកពាមជរ ខេត្តព្រៃវែង ។

**ប្រការ៣.-**

ក្រុមការងារអន្តរក្រសួង ត្រូវបង្កើតលេខាធិការដ្ឋានមួយ ដើម្បីធ្វើជាសេនាធិការ ។

**ប្រការ៤.-**

ក្រុមការងារអន្តរក្រសួង មានសិទ្ធប្រើប្រាស់ត្រាក្រសួងមហាផ្ទៃ ។

**ប្រការ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានក្រុមការងារអន្តរក្រសួង និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ អង្គារ ១៣ កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ